ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៧៥ តាងនាមប្រជារាស្ត្រខ្មែរ

ចុះថ្ងៃទី ២៣ .៩.១៩៩៨ **តុលាការកំពូល**

សាលដីកា បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០០

លេខ : ១៤៣ ដោយមានសមាសភាពដូចតទៅ :

ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០០

១ - ឯកឧត្តម ឌិត . មុន្ទី ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

២ - លោក ប៉ែន . ស៊ុន ជាចៅក្រម

៣ - លោក វឿល . មួន ជាចៅក្រម

៤ - លោក ប្រាក់ . គីមសាន ជាចៅក្រម

៥ - លោក យស់ . សួខឿន ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា . ហុក សុខធុល

តំណាងមហាអយ្យការ

លោក ប៉ែន . សារឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៤៦ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៧៦៣ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ស៊ិន សាន់ ភេទប្រុស អាយុ ៥០ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ ៥៦ ក្រុម-៣៦ សង្កាត់បឹងកេងកង២ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។

ឈ្មោះ ទេព សម្បត្តិ ភេទស្រីអាយុ៤៧ ជាតិខ្មែរ មុខរបរមេផ្ទះទីលំនៅផ្ទះលេខ២២៥ សង្កាត់ទួលស្វាយ-ព្រៃ១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ ស៊ិន សុន ភេទស្រីអាយុ៥៩ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិជ្រោយដង ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

**កម្មវត្ថុបណ្តឹង** : ប្តឹងសុំបែងចែកដីមរតក

បានឃើញបណ្តឹងសាទុក្ខលេខ ៦២ ចុះថ្ងៃទី ២៤ ខែមិនា ឆ្នាំ ១៩៩៨ របស់ឈ្មោះ ទេព សម្បត្តិ និងឈ្មោះ ស៊ិន សាន់ ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ ៤៦ ចុះថ្ងៃទី ១៦ . ០២ . ៩៨ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៧៥ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ០១ . ៨ .៩៥ របស់ដើមចោទថា : ខ្លួនប្តឹងទាមទារកេរ្តិ៍ មរតកពីចុងចំលើយឈ្មោះ ស៊ិន សុន ដោយហេតុថា ដីនេះឪពុកឈ្មោះ ស៊ិន អ៊ី បានបែងចែកអោយកូនតាមចំណែក រៀងៗខ្លួនតាំងពី

គាត់នៅរស់ដោយមានរដ្ឋអំណាចដឹងលឺត្រឹមត្រូវ ។ ក្រោយពីឪពុកស្លាប់បងបង្កើត ឈ្មោះ ស៊ិន សុន បានយកដីនេះទាំងអស់ធ្វើជាកម្មសិទ្ធិដោយមិនព្រមបែងចែកអោយបងប្អូនខ្លួន ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៦ " ក " ចុះថ្ងៃទី ០៦ .០៣ .៩៦ របស់តុលាការខេត្តកណ្តាលបានសំរេចសេចក្តីចំពោះមុខគូក្តីដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលបណ្តឹងសុំបែងចែកមរតករបស់ ដើមចោទទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- សំរេចបែងចែកមរតករបស់ខ្មោចឈ្មោះ ស៊ិន អ៊ុំ អោយសហព័ន្ធ និង ទាយាទតាមចំណែកដូចខាងក្រោម :

ក- នាង នៅ . កើត ជាប្រពន្ធត្រូវបាន ១៦% នៃទ្រព្យដែលជាមរតក ។

ខ- នាង ទេព សម្បត្តិ ជាកូនប្រសារត្រូវបាន ១៦% នៃចំនួនទ្រព្យដែលជាមរតកជាចំណែករបស់ប្តី ឈ្មោះ ស៊ិន-.អ៊ឿម ( ស្លាប់ ) ។

គ- នាង ស៊ិន .សុន ជាកូនទី២ ត្រូវបាន ២០% នៃចំនួនទ្រព្យដែលជាមរតក ។

ឃ- នាង ឈឹម .ផល្លី ជាចៅត្រូវបាន ១៦% នៃចំនួនទ្រព្យដែលជាមរតកជាចំណែករបស់ម្តាយឈ្មោះ ស៊ិន.សឿន ( ស្លាប់ ) ។

ង- ឈ្មោះ ស៊ិន សាន់ ត្រូវបាន ១៦% នៃចំនួនទ្រព្យដែលជាមរតក ។

ច- ឈ្មោះ ស៊ិន .សេង ត្រូវបាន ១៦% នៃចំនួនទ្រព្យដែលជាមរតក ។

៣- បង្គាប់អោយនាងស៊ិន .សុន បង់ប្រាក់ប្រដាប់ក្តីចំនួន ៧០០០រៀលប្រាក់នេះបានកាត់យកពីប្រាក់ដែលដើមចោទបានបង់រួចហើយ ហើយអោយឈ្មោះនេះសងទៅដើមចោទវិញ ។

៤- បង្គាប់អោយនាងស៊ិន .សុន បង់ប្រាក់ប្រដាប់ក្តីចំនួន ១% ( មួយភាគរយ ) នៃតំលៃទ្រព្យដែលជាមរតកដែលបានចែកអោយទៅដើមចោទ ( ៦៤% នៃមរតករួម ) ។

៥- សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេល ២ខែ គិតពីថ្ងៃនេះតទៅ ។

សាលក្រមនេះត្រូវបានឈ្មោះ ស៊ិន សុន ប្តឹងឧទ្ធរណ៍តាមបណ្តឹងចុះថ្ងៃទី ៣ .៤ .៩៦ លើចំនុចសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៤៦ ចុះថ្ងៃទី១៦ .០២ .៩៨ របស់សាលាឧទ្ធរណ៍សំរេចចំពោះមុខដើមចោទ ឈ្មោះ ស៊ិន-សាន់ , ទេព សម្បត្តិ កំបាំងមុខ ឈ្មោះ ស៊ិន សេង , ឈឹម ផល្លី និង ចំពោះមុខចុងចំលើយ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ៣ .៤ .៩៦ របស់ឈ្មោះ ស៊ិន សុន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បដិសេធន៍សាលក្រមរដ្ឋប្បវេណីលេខ ១៦ " ក " ចុះថ្ងៃទី ៦ .៣ .៩៦ របស់តុលាការខេត្តកណ្តាលចោលជាអាសារបង់ ។

៣- បដិសេធន៍ពាក្យបណ្តឹងសុំបែងចែកមរតករបស់ដើមចោទចុះថ្ងៃទី ០១ .៨.៩៥ ចោលជាអាសារបង់ ។

៤- ប្រគល់ដីទំនាស់ស្ថិតនៅភូមិជ្រោយដង ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល អោយឈ្មោះ ស៊ិន សុន កាន់កាប់ជាកម្មសិទ្ធិតទៅ ។

៥- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ១៣០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥០០០៛ និង ចំណាយលើអាជ្ញាធរតុលាការ ចំនួន ៥០០០៛ សរុប ១៣០០០៛ ។ កាលបើហួសបណ្តឹង សាទុក្ខបង្គាប់អោយ

ចុងបណ្ដឹងឧទ្ធរណ៍រួមគ្នាបង់ប្រាក់ ១៣០០០៛ នេះទៅដើមបណ្ដឹងឧទ្ធរណ៍វិញ និង បង្គាប់អោយបង់ពន្ធសមាមាត្រ ១% លើតំលៃដីទំនាស់ ។ ប្រាក់ពន្ធនេះ ៨០% ត្រូវបង់ ចូលថវិការរដ្ឋ និង ២០% ត្រូវបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

៦- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទឈ្មោះ ស៊ិន សាន់ , ទេព សម្បត្តិ កំបាំងមុខឈ្មោះ ស៊ិន សេង , ឈឹម ផល្លី និង ចំពោះមុខចុងចំលើយ ។

បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

សាលដីកានេះត្រូវបានឈ្មោះ ស៊ិន សាន់ និង ឈ្មោះ ទេព សម្បត្តិ ប្ដឹងសាទុក្ខតាមបណ្ដឹងលេខ ៦២ ចុះថ្ងៃទី ២៤ .៣ .៩៨ មិនសុខចិត្តពីសេចក្ដីសំរេចនៃសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៩ របស់ឈ្មោះ ស៊ិន សាន់ និង ឈ្មោះ ទេព សម្បត្តិ ។

បានឃើញសារណាតបចុះថ្ងៃទី៩ ខែមិនា ឆ្នាំ២០០០ របស់ឈ្មោះ ស៊ិន សុន ។

បានស្ដាប់របាយការណ៍របស់ចៅក្រមប្រាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ៤៦ ចុះថ្ងៃទី ១៦ .០២ .៩៨ របស់សាលា ឧទ្ធរណ៍ដែលបានសំរេចសេចក្ដីមកនេះមានការខុសឆ្គងទាំងទំរង់ និង គតិច្បាប់ ។

សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្ដាប់ចំលើយរបស់លោក ស៊ិន សាន់ ជាដើមចោទ និង ជាដើមបណ្ដឹងសាទុក្ខបានឆ្លើយនាពេលសវនាការថា : សាលាឧទ្ធរណ៍កាត់សេចក្ដីពុំត្រឹមត្រូវព្រោះថា ដីនេះជាដីកេរ្ដិ៍របស់ឪពុក ម្ដាយ ខ្លួន ពិតប្រាកដក្រោយឆ្នាំ ១៩៧៩ ឪពុក ម្ដាយខ្លួន បានមករស់នៅលើដីនេះ គឺដីខាងត្បូង និង ខាងជើងផ្លូវ ។នៅឆ្នាំ១៩៩២ ឪពុកខ្លួនបាន ស្លាប់ម្ដាយខ្លួនក៏ហៅកូន១មកវាស់ដីចែកនៅពេលនោះឈ្មោះ ស៊ិន មិនបានជំទាស់ទេមកដល់ពេលនេះគាត់រំលោភសិទ្ធិជំទាស់ ឈប់អោយដីនេះមកពូកខ្លួនវិញ ។សូមតុលាការមេត្តាជួយវិនិច្ឆ័យអោយខ្លួនផងព្រោះដីនេះឪពុកខ្លួនបានបែងចែកតាំងពីគាត់មិនទាន់ ស្លាប់ម៉េះ ។

បានស្ដាប់ចំលើយរបស់អ្នកស្រី ទេព សម្បត្តិ ជាដើមចោទ និង ជាដើមបណ្ដឹងសាទុក្ខបានឆ្លើយនាពេលសវនការថា : ដីនេះខ្លួនត្រូវបានចំណែកពីគាត់ដែរដោយប្ដីខ្លួនគាត់បានស្លាប់ហើយ។ នៅពេលចែកដី នោះគឺឪពុកម្ដាយក្មេកខ្លួនចែកអោយកូន ៣នាក់ គឺដីខាង មាត់ទន្លេតែពេលនេះ ឈ្មោះ ស៊ិន នេះគាត់មិនព្រមអោយដីនោះមកខ្លួនទេ ។

បានស្ដាប់ចំលើយរបស់អ្នកស្រី ស៊ិន សុន ជាចុងចំលើយ និង ជាចុងបណ្ដឹងសាទុក្ខបានឆ្លើយនាពេលសវនាការថា : ដីនេះគឺជាដីរដ្ឋចែកអោយខ្លួនមិនមែនជាដីកេរ្ដិ៍ ឪពុក ម្ដាយទេ ខ្លួន រស់នៅលើដីនេះ តាំងពី ឆ្នាំ១៩៧៩ មកជាមួយ ឪពុក ម្ដាយខ្លួន ហើយខ្លួនជាអ្នកគ្រប់គ្រងឪពុក ម្ដាយខ្លួន ។ ហេតុដែលខ្លួនគ្មានឈ្មោះក្នុងប័ណ្ណគ្រួសារ ព្រោះ ប័ណ្ណគ្រួសារ នោះបានបាត់នៅពេលខ្លួនរវល់ធ្វើបុណ្យសពឪពុកខ្លួន ចោរវាបានលួចយកទៅ ហើយខ្លួនពុំសូវចេះដឹងអ្វីផងក៏ពុំបានធ្វើថ្មី ដែរ ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ចំលើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៦២ ចុះថ្ងៃទី ២៤ .៣ .៩៨ របស់អ្នកស្រីទេព សម្បត្តិ និង លោក ស៊ិន សាន់ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ សំរេចលើកបណ្តឹងទាមទារចែកមរតករបស់ដើមចោទចោល ដោយសំអាងទៅលើសាក្សី និង ម្តាយនៃគូភាគីដែលថាដីនេះរដ្ឋអំណាច បានចែកអោយអ្នកស្រី ស៊ិន សុន និង ស្វាមីនៅឆ្នាំ១៩៩២ នោះជាការភ័ន្តច្រឡំពីព្រោះថា តាមការស៊ើបអង្កេតនៅតុលាការថ្នាក់ក្រោម ដីដែលជាកម្មវត្ថុនៃការប្តឹងសុំបែងចែកនេះជាដីដែល សពលោក ស៊ិន អ៊ី និង អ្នកស្រី នៅ .កើត ដែលត្រូវបានរដ្ឋអំណាចបែងចែកអោយ និង គ្រប់គ្រងតាំងពីឆ្នាំ១៩៧៩-៨០ មកម្លេះ ។ហើយអ្នកស្រី ស៊ិន .សុន និង ស្វាមីទើបតែមករស់នៅលើដីនេះនៅឆ្នាំ១៩៩០ ប៉ុណ្ណោះ ហើយចាប់ពីឆ្នាំ១៩៩០មកក៏ពុំមានភស្តុតាងណាបញ្ជាក់ថា រដ្ឋអំណាចបានធ្វើការបែងចែកដីទៀតដែរ ។

យល់ឃើញថា ទោះជាលោក ស៊ិន អ៊ីទទួលមរណៈភាពហើយក្តី ក៏ភាគីនៅរស់ គឺអ្នកស្រីនៅ កើត ពុំមានសិទ្ធិចាត់ចែងទ្រព្យសម្បត្តិរួមតែម្នាក់ឯងដែរ គឺត្រូវបែងចែកសិទ្ធិចាត់ចែងជាពីរចំណែកស្មើគ្នា ផ្នែកដែលត្រូវបានទៅអ្នកស្រីនៅ កើត អ្នកស្រីរូបនេះអាចចាត់ចែងតាមឆន្ទៈរបស់អ្នកស្រី ឯចំណែកដែលត្រូវបានទៅសពលោក ស៊ិន អ៊ី ត្រូវបានជាមរតក នៃទាយាទទាំងអស់រួមទាំងអ្នកស្រី ស៊ិន សុនផង ។ ម្យ៉ាងទៀតសាលដីកាលេខ ៤៦ ចុះថ្ងៃទី១៦ .០២ .៩៨ របស់សាលាឧទ្ធរណ៍ ជាសាលដីកាកំបាំងមុខឈ្មោះ ស៊ិ ន សេង និង ឈឹម ផល្លី ហើយពុំមាន ឯកសារណាមួយបញ្ជាក់ថា សាលាឧទ្ធរណ៍បានជូនដំណឹងពីសាលដីកានេះដល់ឈ្មោះឈឹម ផល្លី ទេ ។

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៤៦ ចុះថ្ងៃទី១៦ .០២ .៩៨ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ៦២ ចុះថ្ងៃទី២៤ .៣ .៩៨ របស់អ្នកស្រីទេព សម្បត្តិ និង លោកស៊ិន សាន់ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈ សាលដីការដ្ឋប្បវេណីលេខ៤៦ ចុះថ្ងៃទី១៦ .០២ .៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ២៧៥ ចុះថ្ងៃទី ២៣.៩ .៩៨ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩០០០រៀល ដែលដើមចោទបានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធ ហ្វឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីការកោះចំនួន ១៥០០០រៀល សរុប ១៩០០០រៀល ហើយតំរូវអោយចុងចំលើយសងប្រាក់ចំនួន ១៩០០០រៀល នេះទៅដើមចោទវិញ ។

៥- សាលដីកានេះប្រកាសសវនាការជាសាធារណៈនៅថ្ងៃទី០១ ខែ សីហា ឆ្នាំ ២០០០ ។